ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលនយោបាយ
# អភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជា
# ២០២១-២០៣០

**រៀបរៀង និងផ្សព្វផ្សាយដោយ៖**
ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ (ក.ស.ក./MAFF)
អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (អ.ស.ផ.ស./GDAHP)

**គាំទ្រដោយ៖**
អង្គការសហប្រជាជាតិដើម្បីអភិវឌ្ឍន៍ឧស្សាហកម្ម (UNIDO)
កម្មវិធីឡជីវឧស្ម័នជាតិ (NBP)
មជ្ឈមណ្ឌលបច្ចេកវិទ្យា និងព័ត៌មានជីវឧស្ម័នខ្នាតធំ (BTIC)
ក្រុមហ៊ុនដៃគូសម្រាប់នវានុវត្តន៍ (PfI)

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# គោលនយោបាយ
# អភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជា
# ២០២១-២០៣០

ឆ្នាំ ២០២១

# អារម្ភកថា

យើងទាំងអស់គ្នាបានជ្រាបយ៉ាងច្បាស់លាស់ហើយថា បច្ចុប្បន្ននេះដោយសារវិបត្តិជាសាកលបណ្តាលមកពីការឆ្លងរាលដាលនៃជំងឺកូវីដ-១៩ ដែលបានកើតឡើងក្នុងព្រឹត្តិការណ៍សហគមន៍២០កុម្ភៈ ឆ្នាំ២០២១នេះ បានក្លាយជាបញ្ហាប្រឈមមួយធ្វើឱ្យប៉ះពាល់ដល់សង្គម-សេដ្ឋកិច្ចជាតិយើង ជាពិសេសជីវភាពរស់នៅរបស់គ្រួសារក្រីក្រ និងជនងាយរងគ្រោះ។ ក្នុងបរិការណ៍នេះ រាជរដ្ឋាភិបាលកម្ពុជា ក្រោមការដឹកនាំប្រកបដោយគតិបណ្ឌិត និងឈ្លាសវៃបំផុតរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** បានដាក់ចេញនូវវិធានការយ៉ាងមុតស្រួចដើម្បីជួយស្រោចស្រង់ កាត់បន្ថយផលប៉ះពាល់ និងគាំទ្រលើកស្ទួយនូវកំណើនសេដ្ឋកិច្ចជាតិ ដែលក្នុងនោះវិស័យកសិកម្មគឺជាវិស័យអាទិភាពនាំមុខមួយក្នុងចំណោមវិស័យអាទិភាពសំខាន់ៗដទៃទៀតរបស់រាជរដ្ឋាភិបាល ដែលវិស័យនេះបាននិងកំពុងចូលរួមចំណែកយ៉ាងសំខាន់ក្នុងការជំរុញកំណើនសេដ្ឋកិច្ចជាតិ ធានាបាននូវសន្តិសុខស្បៀង ជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ និងលើកកម្ពស់កម្រិតជីវភាពរស់នៅរបស់ប្រជាពលរដ្ឋ ជាពិសេសប្រជាកសិករដែលពឹងអាស្រ័យលើការប្រកបមុខរបរកសិកម្មជាចម្បង។

ដោយឡែក គោលនយោបាយអភិវឌ្ឍន៍វិស័យកសិកម្ម ឆ្នាំ២០២១-២០៣០ ក៏នឹងត្រូវដាក់ចេញឱ្យអនុវត្តនាពេលខាងមុខដោយមានគោលដៅចម្បងគឺបង្កើនតម្លៃបន្ថែម និងបង្កើនផលិតភាពកសិកម្ម ឆ្លើយតបទៅនឹងវឌ្ឍនាការនៃបដិវត្តន៍ឧស្សាហកម្មទី៤ និងបច្ចេកវិទ្យាឌីជីថល ពិសេសក្របខ័ណ្ឌគោលនយោបាយសេដ្ឋកិច្ច និងសង្គមឌីជីថលកម្ពុជាឆ្នាំ២០២១-២០៣៥របស់រាជរដ្ឋាភិបាលក្នុងទស្សនទានថ្មីនៃកិច្ចអភិវឌ្ឍសង្គមសេដ្ឋកិច្ច ដើម្បីធានាបាននូវប្រព័ន្ធស្បៀងឆ្លើយតបទៅនឹងការអភិវឌ្ឍប្រកបដោយចីរភាពនៅកម្ពុជានាឆ្នាំ២០៣០ នេះផងដែរ។

ទន្ទឹមនឹងនេះ កម្មវិធីឡជីវឧស្ម័នជាតិត្រូវបានដំណើរការអនុវត្តចាប់តាំងពីឆ្នាំ២០០៦ ដែលកម្មវិធីនេះគ្រប់គ្រង ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងប្រតិបត្តិដោយអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ។ ឆ្លើយតបនឹងវឌ្ឍនភាពគួរឱ្យកត់សម្គាល់ក្នុងវិស័យជីវឧស្ម័ន ក្រុមការងារបានរៀបចំគោល-នយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០១៦-២០២៥ នៅឆ្នាំ២០១៦ ក្នុងគោលបំណងគ្រប់គ្រង និងអភិវឌ្ឍន៍វិស័យនេះ ប្រកបដោយភាពវៃឆ្លាត នវានុវត្តន៍ និងបរិយាប័ន្ន។ ជាមួយគ្នានេះ វិស័យជីវឧស្ម័នបានឆ្លងកាត់ដំណើរវិវត្តន៍ជាច្រើន ដោយមានការវិនិយោគឡជីវឧស្ម័នខ្នាតធំ មិនមែនមានតែនៅកសិដ្ឋានចិញ្ចឹមសត្វប៉ុណ្ណោះទេ ព្រមទាំងមាននៅតាមសហគ្រាសកសិ-ឧស្សាហកម្មទៀតផង ដូចជារោងចក្រកែច្នៃដំឡូងមី ជាដើម។

ដោយមានភាពចាំបាច់នេះ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានបង្កើតក្រុមការងារបច្ចេកទេសសម្រាប់រៀបចំគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជា កាលពីខែមករា ឆ្នាំ២០២១ កន្លងមក។ ជាលទ្ធផលឯកសារគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០ ត្រូវបានរៀបចំឡើងស្របតាមគោលនយោបាយ និងយុទ្ធសាស្ត្ររបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្នុងគោលបំណងលើកកម្ពស់ការអភិវឌ្ឍ និងការប្រើប្រាស់ឡជីវឧស្ម័នប្រកបដោយប្រសិទ្ធភាព និងនិរន្តរភាព ជាពិសេសចូលរួមអនុវត្តគោលដៅអភិវឌ្ឍន៍ដោយចីរភាពនៅកម្ពុជាដែលជាបរិសទានមួយធ្វើឱ្យបរិស្ថានល្អសម្រាប់អនាគតនៃជីវិតរស់នៅរបស់សត្តនិករទាំងឡាយឱ្យកាន់តែល្អប្រសើរឡើង។

ក្នុងនាមក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ខ្ញុំសូមវាយតម្លៃខ្ពស់ចំពោះកិច្ចខិតខំប្រឹងប្រែងរបស់ថ្នាក់ដឹកនាំក្រសួង ក្រុមការងារបច្ចេកទេសសម្រាប់រៀបចំគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ន អគ្គនាយកដ្ឋាន

សុខភាពសត្វ និងផលិតកម្មសត្វ និងគ្រប់ដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធទាំងអស់ដែលបានចូលរួមគាំទ្រ ក្នុងការរៀបចំគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាដ៏មានសារៈសំខាន់នេះឡើង។ ទោះជាយ៉ាងណា ខ្ញុំជឿជាក់ថាឯកសារគោលនយោបាយដែលបានរៀបចំចងក្រងនេះពិតជានៅមានចំណុចខ្វះខាតនៅឡើយរួមទាំងអក្ខរាវិរុទ្ធ និងខ្លឹមសារ ជាដើម។ ជាមួយនេះដែរ ខ្ញុំរង់ចាំទទួលដោយរីករាយនូវមតិស្ថាបនាពីប្រិយមិត្តអ្នកអានដោយមេត្រីភាព។

ជាថ្មីម្តងទៀត ខ្ញុំសូមលើកទឹកចិត្តឱ្យគ្រប់ភាគីពាក់ព័ន្ធទាំងអស់ ចូលរួមអនុវត្តគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០ ឱ្យមានប្រសិទ្ធភាពខ្ពស់ ដើម្បីឱ្យគ្រួសារកសិករ សហគមន៍ជនបទ និងកសិធុរជនមានជីវភាពរស់នៅកាន់តែប្រសើរឡើង និងបង្កើនផលចំណេញពីធុរកិច្ចរបស់ខ្លួន ក្នុងបរិស្ថានល្អនិងមាននិរន្តរភាព តាមរយៈការប្រើប្រាស់ឡជីវឧស្ម័នប្រកបដោយប្រសិទ្ធភាព សុវត្ថិភាព និងចីរភាព។

ថ្ងៃអង្គារ ៥រោច ខែអស្សុជ ឆ្នាំឆ្លូវ ត្រីស័ក. ព.ស ២៥៦៥

រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ តុលា ឆ្នាំ២០២១

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

# មាតិកា


អារម្ភកថា

១. សេចក្តីផ្តើម ........................................ ១

១.១ ស្ថានភាព និងការព្យាករណ៍នៃអនុវិស័យចិញ្ចឹមសត្វ ........................................ ២

១.២ ស្ថានភាពនៃឧស្សាហកម្មកែច្នៃកសិផល ........................................ ៤

១.៣ វិស័យកសិកម្ម និងការប្រែប្រួលអាកាសធាតុ ........................................ ៥

១.៤ ស្ថានភាពនៃការអភិវឌ្ឍឡជីវឧស្ម័ននៅកម្ពុជា ........................................ ៦

១.៥ កាលានុវត្តភាព និងការប្រឈម ........................................ ១០

១.៦ ឡជីវឧស្ម័ននិងការរួមចំណែកដល់គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពកម្ពុជា........................................ ១២

២. ចក្ខុវិស័យ ........................................ ១៣

៣. គោលបំណង និងគោលដៅ ........................................ ១៣

៣.១ គោលបំណង ........................................ ១៣

៣.២ គោលដៅ........................................ ១៣

៤. យុទ្ធសាស្ត្រដើម្បីសម្រេចគោលដៅ ........................................ ១៤

៤.១ ពង្រឹងការងារអភិបាលកិច្ច ........................................ ១៤

៤.២ ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន ........................................ ១៥

៤.៣ លើកកម្ពស់គុណភាពឡជីវឧស្ម័ន និងប្រយោជន៍ឡជីវឧស្ម័ន ........................................ ១៥

៤.៤ លើកកម្ពស់ការលើកទឹកចិត្ត និងការឧបត្ថម្ភធន ........................................ ១៦

៤.៥ បង្កើនទីផ្សារឥណទានកាបូនដើម្បីកាត់បន្ថយការបំភាយឧស្ម័នផ្ទះកញ្ចក់........................................ ១៧

៥. ផែនការសកម្មភាព ........................................ ១៧

៥.១ ការបង្កើតយន្តការអនុវត្តន៍ ........................................ ១៧

៥.២ ក្របខ័ណ្ឌគតិយុត្ត ........................................ ២២

៥.៣ ហិរញ្ញវត្ថុ ........................................ ២២

៥.៤ ការអភិវឌ្ឍធនធានមនុស្ស ........................................ ២៣

៥.៥ ការអនុវត្តគោលនយោបាយ ........................................ ២៤

៥.៥.១ ជំរុញការសាងសង់ និងប្រើប្រាស់ឡជីវឧស្ម័ន ........................................ ២៤

៥..៥.២ ជំរុញអភិបាលកិច្ច ការសម្របសម្រួល និងការធ្វើរបាយការណ៍ ........................................ ២៦

៥.៥.៣ លើកកម្ពស់ហេដ្ឋារចនាសម្ព័ន្ធគុណភាពឡជីវឧស្ម័ន ........................................ ២៧

៥.៥.៤ យន្តការគាំទ្រសារពើពន្ធ និងមិនមែនសារពើពន្ធ ........................................ ២៧

៥.៥.៥ បង្កើតនិងជំរុញសហគមន៍អ្នកប្រើប្រាស់ឡជីវឧស្ម័ន ........................................ ២៩

៥.៥.៦ ជំរុញការស្រាវជ្រាវ អភិវឌ្ឍន៍ និងការប្រើប្រាស់ឡជីវឧស្ម័ន ........................................ ២៩

៥.៥.៧ បង្កើនការវិភាជន៍ថវិកាទៅអគ្គនាយដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ដើម្បីអភិវឌ្ឍន៍ជីវឧស្ម័ន........................................ ៣០

៥.៥.៨ ការកៀរគរហិរញ្ញប្បទានអាកាសធាតុ ........................................ ៣០

៦. ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃគោលនយោបាយ ............ ៣១
៧. សេចក្តីសន្និដ្ឋាន ............ ៣២
ពាក្យសរសេរកាត់ ............ ៣៤
ឧបសម្ព័ន្ធ "ក" ម៉ាទ្រីសនៃការអនុវត្តក្របខ័ណ្ឌគតិយុត្ត............ ៣៦
ឧបសម្ព័ន្ធ "ខ" ម៉ាទ្រីសនៃវិធានការគោលនយោបាយ និងផែនការសកម្មភាព............៣៧
សន្ទានុក្រម ............៥០

# គោលនយោបាយ
# អភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជា ២០២១ - ២០៣០

## ១. សេចក្តីផ្តើម

ប្រទេសកម្ពុជាបានឆ្លងកាត់ការអភិវឌ្ឍសង្គម និងសេដ្ឋកិច្ចបានយ៉ាងឆាប់រហ័សដោយសារការរក្សាបាននូវសន្តិភាព និងស្ថិរភាពនៃកំណើនសេដ្ឋកិច្ចរឹងមាំ ក្នុងរយៈពេលប៉ុន្មានទសវត្សថ្មីៗនេះ។ រាជរដ្ឋាភិបាលមានចក្ខុវិស័យក្នុងការប្រែក្លាយកម្ពុជាទៅជាប្រទេសដែលមានប្រាក់ចំណូលមធ្យមកម្រិតខ្ពស់នៅឆ្នាំ២០៣០។ ឆ្លើយតបនឹងចក្ខុវិស័យនេះ វិស័យកសិកម្ម ត្រូវបានចាត់ទុកជា វិស័យអាទិភាពមួយនៅក្នុងរបៀបវារៈអភិវឌ្ឍន៍ជាតិ ដូចដែលមានចែងក្នុងយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៤ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិឆ្នាំ២០១៩ -២០២៣។

កំណើននៃវិស័យកសិកម្មបានកើនឡើងគួរឱ្យកត់សម្គាល់ក្នុងរង្វង់អត្រា៤%ក្នុងមួយឆ្នាំនៅអំឡុងឆ្នាំ២០១១-២០១៧[១] បើទោះបីជាការរួមចំណែករបស់វិស័យនេះទៅក្នុងផលិតផលក្នុងស្រុកសរុប (ផសស)បានធ្លាក់ចុះប្រមាណ ១,៨%ក្នុងមួយឆ្នាំក៏ដោយ តែវិស័យនេះ នៅតែជាវិស័យចម្បងមួយក្នុងចំណោមវិស័យដទៃទៀត ដោយការបង្កើតការងារក្នុងស្រុក(៣៧%នៃកម្លាំងពលកម្មសរុប) និងប្រាក់ចំណូលនៅតំបន់ជនបទ។

ផែនការមេកវិស័យកសិកម្មឆ្នាំ២០៣០បានបង្ហាញនូវចក្ខុវិស័យសម្រាប់អភិវឌ្ឍន៍វិស័យកសិកម្ម៖ កសិកម្មកម្ពុជាជាកសិកម្មទំនើបកម្មមានលក្ខណៈប្រកួតប្រជែង បរិយាប័ន្ន ធន់នឹងការប្រែប្រួលអាកាសធាតុ និងនិរន្តភាពដែលនាំ ដល់ការកើនឡើងប្រាក់ចំណូលគ្រួសារកសិករ វិបុលភាព និងសុខមាលភាពរបស់ប្រជាពលរដ្ឋ។ ក្នុងនោះមានគោលដៅសំខាន់គឺ ១) ជំរុញកំណើន នៃតម្លៃបន្ថែមរបស់វិស័យកសិកម្មទៅក្នុងសេដ្ឋកិច្ចជាតិក្នុងរង្វង់ ៣%ក្នុងមួយឆ្នាំ និង ២) បង្កើនផលិតភាពពលកម្មក្នុងវិស័យកសិកម្មពី ១.៩៨៦ដុល្លារអាមេរិក ក្នុងឆ្នាំ២០១៩ ដល់ ៤.៦២៥ ដុល្លារអាមេរិក/មនុស្សម្នាក់ នៅឆ្នាំ២០៣០។ ក្នុងកម្រិតយុទ្ធសាស្ត្រ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ បានអនុម័តផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣ ដោយកំណត់តម្លៃបន្ថែមសរុបរបស់វិស័យកសិកម្ម (Gross Value Added-GVA) សម្រេចបានក្នុងរង្វង់ ៣% ទៅ ៥%ក្នុងមួយឆ្នាំ និងមានការព្យាករណ៍នៃគោលដៅកំណើនវិស័យកសិកម្មនឹងត្រូវសម្រេចឱ្យបានក្នុងរង្វង់៤%ក្នុង មួយឆ្នាំ ។ យុទ្ធសាស្ត្រគន្លឹះដើម្បីសម្រេចបានគោលដៅកំណើននេះរួមមាន ការកែលម្អផលិតភាព ពិពិធកម្ម និង ពាណិជ្ជូបនីយកម្មនៃវិស័យកសិកម្ម ការចិញ្ចឹមសត្វ និងវារីវប្បកម្មប្រកបដោយចីរភាព ព្រមទាំងអភិរក្ស និងការពារ ព្រៃឈើ និងជលផលផងដែរ។

អនុវិស័យចិញ្ចឹមសត្វ បានដើរតួនាទីចម្បងទី៣ ក្នុងការរួមចំណែកដល់កំណើននៃវិស័យកសិកម្ម ដែលបានកើនឡើង ១១% ក្នុងអំឡុងឆ្នាំ២០១០-២០១៩[២]។ ប្រកាសលេខ៥៤៩ត្រូវបានបង្កើតឡើងដើម្បីធានាឱ្យបាននូវការផ្គត់ផ្គង់ផលិតផលសត្វប្រកបដោយចីរភាព ទាំងគុណភាព និងបរិមាណសម្រាប់ទីផ្សារក្នុងស្រុក និងនាំចេញ។ ប្រកាសនេះក៏បានកំណត់ចំណាត់ថ្នាក់កសិដ្ឋាន បង្កើតបទប្បញ្ញត្តិបច្ចេកទេស និងនីតិវិធីសម្រាប់ផលិតកម្មបសុសត្វ និងជាពិសេស ការតម្រូវឱ្យមានកន្លែងប្រព្រឹត្តកម្មជីវសាស្ត្រ និងការគ្រប់គ្រងលាមកសត្វ។ប្រកាសនេះតម្រូវឱ្យ

---

*[១] ធ្លាក់ចុះពី ៥.៨% ក្នុងមួយឆ្នាំ នៅចន្លោះឆ្នាំ២០០៤-២០១០។ ការចូលរួមរបស់វិស័យនេះទៅក្នុងផ.ស.សបានថយចុះពី៣៤.៦% នៅឆ្នាំ២០១១ទៅ២៣.៦% នៅឆ្នាំ២០១៧។*

*[២] ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍វិស័យកសិកម្មឆ្នាំ២០១៩-២០២៣*

កសិដ្ឋានបែបពាណិជ្ជកម្ម ទាំងអស់ត្រូវគោរពតាមបទដ្ឋានបច្ចេកទេស ដែលរាប់បញ្ចូលទាំងប្រព័ន្ធជីវសុវត្ថិភាព ការគ្រប់គ្រងសំណល់លាមកសត្វ អនាម័យ និងកិច្ចការពារបរិស្ថាន រួមមានការបង្ការក្លិនសាយភាយ និងសំលេងរំខានជាដើម។

ក្រៅពីអនុវិស័យចិញ្ចឹមសត្វ គោលនយោបាយជីវឧស្ម័ននេះក៏នឹងគាំទ្រដល់ការអនុវត្តន៍នៃគោលនយោបាយជាតិ ស្តីពីជំឡូងមី និងគោលនយោបាយអភិវឌ្ឍន៍ឧស្សាហកម្មផងដែរជាពិសេសទាក់ទងនឹងការជួយគាំទ្របណ្តារោងចក្រ កែច្នៃកសិផលឱ្យមានប្រព្រឹត្តិកម្មសំណល់រាវ តាមរយៈ ប្រព័ន្ធជីវឧស្ម័ន ដើម្បី ទាញ យក ថាមពល សម្រាប់ប្រើប្រាស់ក្នុង ដំណើរការផលិតកម្ម។ ទាំងអស់នេះ នឹងជួយកែលម្អសមិទ្ធកម្មសេដ្ឋកិច្ចរបស់រោងចក្រទាំងនេះឱ្យប្រសើរឡើង បង្កើន ការធ្វើពាណិជ្ជកម្ម និងនវានុវត្តន៍។ ក្នុងកម្រិតអន្តរជាតិ គោលនយោបាយនេះមានទំនាក់ទំនងយ៉ាងជិតស្និទ្ធទៅនឹងរបាយការណ៍បច្ចុប្បន្នភាពនៃការចូលរួមចំណែករបស់កម្ពុជា ក្នុងការឆ្លើយតបទៅនឹងការប្រែប្រួលអាកាសធាតុ រួម បញ្ចូល ទាំង ការ កាត់ បន្ថយ ការ បញ្ចេញ ឧស្ម័ន ផ្ទះកញ្ចក់ និង បង្កើន ភាព ធន់ នឹង ការ ប្រែប្រួលអាកាសធាតុ។

ដោយសារមានការរីកចម្រើនយ៉ាងឆាប់ រហ័ស ក្នុង វិស័យ ជីវឧស្ម័ន និងការប្រែប្រួលសេដ្ឋកិច្ចជនបទទើបគោលនយោបាយ អភិវឌ្ឍន៍ ឡជីវឧស្ម័ន នៅ កម្ពុជា ឆ្នាំ២០១៦-២០២៥ ត្រូវ បាន ធ្វើ បច្ចុប្បន្នភាព និងជំនួសដោយគោលនយោបាយអភិវឌ្ឍន៍ឡជីវឧស្ម័ននៅកម្ពុជាឆ្នាំ២០២១-២០៣០។ ម្យ៉ាងទៀតគោលនយោបាយអភិវឌ្ឍន៍ឡជីវ-ឧស្ម័ននៅកម្ពុជាថ្មីនេះក៏ត្រូវបានបន្សីជាមួយផែនការអភិវឌ្ឍវិស័យកសិកម្មឆ្នាំ២០១៩-២០២៣ គោលនយោបាយ និងផែនការអភិវឌ្ឍន៍ វិស័យដទៃទៀតដែលពាក់ព័ន្ធនឹងជីវឧស្ម័ន។ គោលនយោបាយថ្មីនេះនឹងផ្តល់នូវគោលបំណង និងគោលដៅច្បាស់លាស់ដើម្បីផ្តល់ទិសដៅ និងជួយពន្លឿនការប្រើប្រាស់ឡជីវឧស្ម័នគ្រប់ទំហំទាំងអស់នៅក្នុងអនុ-វិស័យចិញ្ចឹមសត្វ និងវិស័យកែច្នៃ កសិផលដទៃទៀតនៅកម្ពុជា។

## ១.១ ស្ថានភាព និងការព្យាករណ៍នៃអនុវិស័យចិញ្ចឹមសត្វ

តារាងទី១ បង្ហាញពីស្ថិតិផលិតកម្មសត្វតាមប្រភេទនៃការចិញ្ចឹម និងការប្រែប្រួលនៃការចិញ្ចឹមសត្វនៅក្នុងអំឡុង ឆ្នាំ២០១៦-២០២០។ តារាងនេះបង្ហាញថា ការចិញ្ចឹមសត្វជាលក្ខណៈគ្រួសារនៅតែជាអ្នកផ្គត់ផ្គង់ផលិតផលសត្វចម្បងនៅឡើយលើកលែងតែការចិញ្ចឹមជ្រូក។ កសិដ្ឋាន ចិញ្ចឹម ជ្រូក ជា លក្ខណៈ ពាណិជ្ជកម្មបានក្លាយ ជា អ្នកផ្គត់ផ្គង់ជ្រូក(សាច់ជ្រូក)សំខាន់ជាងគេបន្តិចម្តងៗ។ ការចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មបានកើនឡើងដល់ទៅ ៥៥%នៅឆ្នាំ២០២០ (កើន ឡើងពីចំនួន ៥៩៩ ៣៤១ក្បាល នៅឆ្នាំ២០១៦ ទៅ ១ ៣៧៩ ៦២៣ក្បាល នៅឆ្នាំ ២០២០)។ គិតត្រឹមឆ្នាំ២០២០តួលេខកសិដ្ឋានចិញ្ចឹមជ្រូកជាលក្ខណៈពាណិជ្ជកម្មសរុបមានចំនួន៥៥១កសិដ្ឋាន ដែល ក្នុង នោះ ភាគ ច្រើន ជា កសិដ្ឋាន ចិញ្ចឹមជ្រូកយកសាច់ (៤៨៩កសិដ្ឋាន) និង កសិដ្ឋានចិញ្ចឹមជ្រូកពូជ (៦២កសិដ្ឋាន)[៣]។

---

[៣] *របាយការណ៍បូកសរុបលទ្ធផលការងារផលិតកម្មសត្វនិងផលិតកម្មសត្វ អគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ (២០២១)*